**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ:** ០១៣ **គ.ជ.ប.** ស.ន.ល

# សេចក្តីជូនដំណឹង

## ស្តីពី

## ការកំណត់ចំនួនឃុំ សង្កាត់ និងចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៦ ឆ្នាំ២០២៧

អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ អនុក្រឹត្យលេខ១០៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៦ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៦ និងសេចក្តីសម្រេចលេខ១១ សសរ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៦ **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (**គ.ជ.ប**) សូមជម្រាបជូនដំណឹងជាសាធារណៈដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសជ្រាបថា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅ**ថ្ងៃអាទិត្យ ទី៦ ខែមិថុនា ឆ្នាំ២០២៧** ខាងមុខនេះ ចំនួនឃុំ សង្កាត់ និងចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំណុះរាជធានី ខេត្ត ត្រូវបានកំណត់ដូចខាងក្រោម៖

| ល.រ | រាជធានី ខេត្ត | ចំនួនឃុំ សង្កាត់ | ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ |
|---|---|---|---|
| ០១ | បន្ទាយមានជ័យ | ៦៧ | ៥៣៣ |
| ០២ | បាត់ដំបង | ១០៣ | ៨២៣ |
| ០៣ | កំពង់ចាម | ១០៩ | ៨១៧ |
| ០៤ | កំពង់ឆ្នាំង | ៧១ | ៤២៧ |
| ០៥ | កំពង់ស្ពឺ | ៨៨ | ៦១៦ |
| ០៦ | កំពង់ធំ | ៨១ | ៥៨៥ |
| ០៧ | កំពត | ៩៣ | ៥៦១ |
| ០៨ | កណ្តាល | ១២៧ | ៩១៥ |
| ០៩ | កោះកុង | ២៩ | ១៦៧ |
| ១០ | ក្រចេះ | ៤៨ | ៣០០ |
| ១១ | មណ្ឌលគិរី | ២១ | ១០៧ |
| ១២ | ភ្នំពេញ | ១០៥ | ៨៩៩ |
| ១៣ | ព្រះវិហារ | ៥១ | ៣៣៣ |



មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ, កម្ពុជា
Samdach Sothearos Blvd, Sangkat Tonle Bassac, Khan Chamkar Morn, Phnom Penh, Cambodia
ទូរសព្ទ : (+855) 23 23 52 53
អ៊ីម៉ែល : info@nec.gov.kh

| | | | |
|---|---|---|---|
| ១៤ | ព្រៃវែង | ១១៦ | ៨៩២ |
| ១៥ | ពោធិ៍សាត់ | ៤៩ | ៣៤១ |
| ១៦ | រតនគិរី | ៥០ | ២៦០ |
| ១៧ | សៀមរាប | ១០០ | ៦៦៨ |
| ១៨ | ព្រះសីហនុ | ២៩ | ១៧៧ |
| ១៩ | ស្ទឹងត្រែង | ៣៤ | ១៧៦ |
| ២០ | ស្វាយរៀង | ៨០ | ៥១៨ |
| ២១ | តាកែវ | ១០០ | ៧៣៦ |
| ២២ | កែប | ៥ | ៣១ |
| ២៣ | ប៉ៃលិន | ៨ | ៥២ |
| ២៤ | ឧត្ដរមានជ័យ | ២៤ | ១៥២ |
| ២៥ | ត្បូងឃ្មុំ | ៦៤ | ៥៣៦ |
| **សរុបរួម** | | **១,៦៥២** | **១១,៦២២** |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នពាក់ព័ន្ធ គណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រជាពលរដ្ឋខ្មែរនៅទូទាំងប្រទេសជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១២ រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០២៦

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**